# ការទិញបន្ទាប់ពីការរឹបអូស ឬការក្ស័យធន

អ្នកអាចទិញផ្ទះបន្ទាប់ពីការរឹបអូស ឬការក្ស័យធនបាន។

REALTOR® អាចជួយអ្នកឲ្យត្រឡប់ទៅផ្លូវទៅកាន់ភាពជាម្ចាស់ផ្ទះវិញបាន។

## តើការរឹបអូស ឬការក្ស័យធនប៉ះពាល់ដល់ឥណទានយ៉ាងដូចម្តេចខ្លះ?

- ព័ត៌មានលម្អិតអាចស្ថិតនៅលើរបាយការណ៍អំពីឥណទានរបស់អ្នកក្នុងរយៈពេល 7-10 ឆ្នាំ។
- ពុំមានចំនួន ឬរូបមន្តជាក់លាក់ណាមួយដើម្បីដឹងអំពីកម្រិតដែលវាអាចប៉ះពាល់ដល់ពិន្ទុនៃកម្រិតឥណទានរបស់អ្នកឡើយ។
- ជាដំបូង វានឹងមានការលំបាកក្នុងការទទួលបានការឯកភាពសម្រាប់ការស្នើសុំឥណទាន។
- ការជួសជុលឥណទាន និងការបង្កើតឥណទានឡើងវិញ គឺជាផ្នែកដ៏សំខាន់មួយនៃការរៀបចំទិញផ្ទះម្តងទៀត។

## តើអ្នកអាចបង្កើតឥណទានរបស់អ្នកឡើងវិញបានដោយរបៀបណា?

- និយាយទៅកាន់ REALTOR® អំពីអ្នកជំនាញ/ក្រុមហ៊ុនជួសជុលឥណទានដ៏ល្បីល្បាញ។
- ត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ឥណទានពីការិយាល័យធ្វើរបាយការណ៍ចំនួនបី (3) ដើម្បីត្រួតពិនិត្យមើលភាពត្រឹមត្រូវ។
- ចងចាំថា ពិន្ទុនៃកម្រិតឥណទានរបស់អ្នកអាចមានភាពប្រសើរឡើងតាមពេលវេលា។
- អនុវត្តតាមផែនការថវិកា ឬផែនការចំណាយប្រចាំខែ។
- បង់ថ្លៃវិក្កយបត្រឲ្យបានទាន់ពេលវេលាគ្រប់ពេល។
- បង្កើតការសន្សំប្រាក់របស់អ្នក។ សូម្បីតែប្រាក់ក្នុងចំនួនតិចតួចជារៀងរាល់ខែក៏នឹងអាចជួយបានដែរ។
- កាត់បន្ថយ ឬលុបបំបាត់បំណុលដែលនៅសល់របស់អ្នក។
- រក្សាការងាររបស់អ្នក (ល្អបំផុត ជាមួយនិយោជកបច្ចុប្បន្នរបស់អ្នក ឬនៅក្នុងផ្នែកដូចគ្នា)។

## តើអ្នកផ្តល់ប្រាក់កម្ចីនឹងពិចារណាអំពីអ្វីខ្លះ?

- អ្នកផ្តល់ប្រាក់កម្ចីភាគច្រើនតម្រូវឲ្យអ្នកដាក់ពាក្យសុំខ្ចីប្រាក់រង់ចាំជាអប្បបរមាពី 1-7 ឆ្នាំ (អាស្រ័យតាមកាលៈទេសៈ) ចាប់ពីពេលមានកំណត់ត្រានៃការរឹបអូស ឬការរួចផុតពីការក្ស័យធន មុនពេលដាក់ពាក្យស្នើសុំធ្វើការបញ្ចាំថ្មី។ និយាយទៅកាន់អ្នកផ្តល់ប្រឹក្សាអំពីការបញ្ចាំរបស់អ្នកដើម្បីត្រួតពិនិត្យឡើងវិញនូវគោលការណ៍ណែនាំបច្ចុប្បន្ន។
- ករណីលើកលែងអាចកើតឡើងផ្អែកតាមស្ថានភាព។
- ពួកគេនឹងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើវិធីដែលអ្នកគ្រប់គ្រងឥណទានរបស់អ្នកចាប់តាំងពីពេលរឹបអូស ឬក្ស័យធន។
- អ្នកផ្តល់ប្រាក់កម្ចីនឹងតែងតែស្នើសុំការពន្យល់អំពីមូលហេតុដែលនាំឲ្យមានការរឹបអូស ឬការក្ស័យធនដើម្បីកំណត់អំពីលទ្ធភាពដែលវាអាចកើតឡើងម្តងទៀត។

## តើខ្ញុំគួររំពឹងអ្វីខ្លះនៅក្នុងការបញ្ចាំ?

- ជាដំបូង អ្នកទំនងជានឹងត្រូវបង់ការប្រាក់ខ្ពស់ជាងមុនបន្តិច។
- ចងចាំថា ការទូទាត់ប្រាក់របស់អ្នកនៅតែអាចតិចជាងថ្លៃឈ្នួល ហើយមានផលប្រយោជន៍ជាច្រើននៃភាពជាកម្មសិទ្ធិផ្ទះ។
- អាចមានកម្មវិធីជួយបង់ប្រាក់មួយផ្នែកមុនដើម្បីជួយអ្នកឲ្យសម្រេចតាមវត្ថុបំណងរបស់អ្នក។

ទាក់ទង **REALTOR®** ណាមួយដើម្បីចាប់ផ្តើមកិច្ចសន្ទនានៅថ្ងៃនេះ!

**ឆ្លាក់ខារភាន់តែល្អ ♦ សហគមន៍ភាន់តែល្អ**

សមាគមន៍ REALOR® នៅតំបន់ SAINT PAUL